KINGDOM OF CAMBODIA
NATION RELIGION KING

MINISTRY OF FOREIGN AFFAIRS
AND INTERNATIONAL COOPERATION

No. PR 46 /2025 MFA.IC

PRESS RELEASE

# Outcomes of the ASEAN Foreign Ministers' Meeting, 30th ASEAN Political-Security Community Council Meeting, 37th ASEAN Coordinating Council Meeting, and Joint ASEAN Foreign and Economic Ministers' Meeting 25 October 2025, Kuala Lumpur, Malaysia

On 25 October 2025, **His Excellency Deputy Prime Minister PRAK Sokhonn**, Minister of Foreign Affairs and International Cooperation, attended the ASEAN Foreign Ministers' Meeting (AMM), 30th ASEAN Political-Security Community (APSC) Council Meeting, 37th ASEAN Coordinating Council (ACC) Meeting, and Joint ASEAN Foreign and Economic Ministers' Meeting in Kuala Lumpur, Malaysia.

## I. ASEAN Foreign Ministers' Meeting (AMM)

The Meeting reaffirmed the commitment to advancing ASEAN Community building towards the realisation of the ASEAN Community Vision 2045 adopted earlier this year. The Meeting discussed developments under the Treaty of Amity and Cooperation in Southeast Asia (TAC) and reiterated the importance of strengthening ASEAN Centrality in ASEAN's engagements with external partners. The Meeting also discussed the Follow-up to the ASEAN Leaders' Review and Decision on the Implementation of the Five-Point Consensus (5PC) and reaffirmed the 5PC as the main reference for ASEAN to address the situation in Myanmar.

The Meeting looked forward to welcoming Timor-Leste as a full member of ASEAN as Timor-Leste deposited its Instrument of Accession to the ASEAN Charter and Instrument of Accession to the Treaty on the Southeast Asia Nuclear Weapon-Free Zone (SEANWFZ). The Meeting adopted the Recommendations to Revitalise the ASEAN Regional Forum (ARF).

**His Excellency Deputy Prime Minister** underscored that the achievements under Malaysia's Chairmanship of ASEAN 2025 embodies the shared aspiration to build a more cohesive, resilient and people-centred ASEAN Community. He further stressed that the realisation of a future-ready and sustainable ASEAN rests upon the strong commitment to dialogue, mutual respect and the peaceful resolution of disputes in accordance with international law, the UN Charter and ASEAN Charter.


Address : N° 3, Samdech HUN Sen Street,
Sangkat Tonle Bassac, Khan Chamkarmon
Phnom Penh, Kingdom of Cambodia
Tel : (855) 23 216 122
Fax : (855) 23 216 141, 023 213 341
Email : mfaic@mfaic.gov.kh

As 2026 will be the 50th Anniversary of the TAC, **His Excellency Deputy Prime Minister** emphasised that the Treaty remains an enduring framework that promotes inclusivity, trust and partnership, not only among ASEAN Member States but also with all external partners. He also reaffirmed support for Türkiye to become a Dialogue Partner of ASEAN, and underscored the importance of broadening engagement with potential partners in the context of the evolving global landscape and ASEAN's continued growth as a dynamic Community.

## II. The 30th ASEAN Political-Security Community (APSC) Council Meeting

The Meeting reviewed the progress in the implementation of the APSC Blueprint 2025 and endorsed its End-Term Review (ETR) Report. The Meeting reaffirmed the commitment to fully implement the APSC Strategic Plan 2045 and improve its implementation based on the recommendations of the ETR.

**His Excellency Deputy Prime Minister** highlighted that the conclusion of the APSC Blueprint 2025 marks a pivotal transition towards the ASEAN Community Vision 2045, which is anchored in resilience, innovation, dynamism and a people-centered approach. He underlined the importance of leveraging ASEAN's convening power to promote dialogue, preventive diplomacy and constructive engagement through ASEAN-led mechanisms.

**His Excellency Deputy Prime Minister** also reaffirmed Cambodia's commitment to strengthening regional and international cooperation against cybercrime and advancing the Women, Peace and Security (WPS) Agenda. While welcoming the successful convening of the 2nd ASEAN WPS Summit, he commended Malaysia's leadership in promoting the meaningful participation of women in peace and security processes, which reaffirms ASEAN's collective commitment to empowering women as key contributors to peace and resilience.

## III. The 37th ASEAN Coordinating Council (ACC) Meeting

Looking forward to the official admission of Timor-Leste into ASEAN on 26 October 2025, the Meeting commended significant progress of Timor-Leste in acceding to ASEAN legal instruments, enhancing institutional readiness, and actively engaging across all three Community pillars. The Meeting encouraged continued support for Timor-Leste, particularly through contributions to the Timor-Leste Unit at the ASEAN Secretariat, and emphasised the importance of fulfilling all criteria outlined in the Roadmap on Timor-Leste's Full Membership in ASEAN. The Meeting also discussed the preparation for the upcoming 47th ASEAN Summit and Related Summits.

**His Excellency the Deputy Prime Minister Prak Sokhonn** emphasised ASEAN's commitment to building an inclusive Community that leaves no one behind. He called for stronger mutual trust among Member States and the safeguarding of ASEAN Centrality and unity in engaging external partners. To achieve these goals, he urged ASEAN to

strengthen institutional capacity, mobilise resources efficiency, and establish mechanisms to monitor and ensure effective implementation of its initiatives.

In addition, **His Excellency Deputy Prime Minister** reaffirmed Cambodia's support for deeper regional economic integration, greater supply chain resilience, and innovation-driven growth. He also expressed Cambodia's full support for the Chair's proposed deliverables for the upcoming 47th ASEAN Summit and Related Summits.

## IV. Joint ASEAN Foreign and Economic Ministers' Meeting

The Meeting noted the briefing by the ASEAN Geoeconomics Task Force ( AGTF ), and called for greater synergy across both political and economic pillars to synchronise the strategies in navigating an increasingly complex and fragmented geopolitical and geoeconomic landscape. The Meeting also urged for the AGTF's recommendations to be anchored in the forthcoming ASEAN Economic Community ( AEC ) Strategic Plan ( 2026-2030 ) in order to ensure coherence with ASEAN's broader vision of a resilient, inclusive, and sustainable regional economy.

During the Meeting, **His Excellency Deputy Prime Minister PRAK Sokhonn** underscored the importance of strengthening ASEAN unity and promoting cross-pillar coordination to effectively address the growing intersection of economic and security concerns. He emphasised the need for a genuine cross-pillar approach – linking the political, security and economic dimensions of ASEAN cooperation.

Reaffirming Cambodia's steadfast support for multilateralism and the principles of the WTO, **His Excellency Deputy Prime Minister** encouraged ASEAN to play a more active role in shaping global rules governing digital trade, investment facilitation and the green transition. He further called for deeper regional integration through enhancing intra-ASEAN trade, connectivity, digital transformation, and the timely implementation of key frameworks such as the AEC Strategic Plan ( 2026-2030 ), the ASEAN Digital Economy Framework Agreement, and relevant regional free trade agreements ( FTAs ).

## V. Signing Ceremony of the Instrument of Accession to the Treaty of Amity and Cooperation in Southeast Asia ( TAC )

On the sidelines of the Meeting, **His Excellency Deputy Prime Minister PRAK Sokhonn** and other ASEAN Foreign Ministers witnessed the Signing Ceremony of the Instrument of Accession to the TAC by the Republic of Finland. **Her Excellency Elina Valtonen**, Minister of Foreign Affairs of the Republic of Finland, affirmed the commitment to ASEAN's values and principles of peaceful coexistence, mutual respect, and friendly cooperation in Southeast Asia.

## VI. Bilateral Meeting on the Sidelines of the Meetings

**His Excellency Deputy Prime Minister PRAK Sokhonn** held a bilateral meeting with **Her Excellency Ma. Theresa P. Lazaro**, Secretary of Foreign Affairs of the Philippines, during which they recalled the productive and successful state visit to Cambodia by **His Excellency Ferdinand Romualdez Marcos Jr.**, President of the Philippines in September

**Excellency Ferdinand Romualdez Marcos Jr.**, President of the Philippines in September 2025, and exchanged views on the establishment of the ASEAN Observer Team ( AOT ) to monitor the full and effective implementation of the ceasefire between Cambodia and Thailand. **His Excellency Deputy Prime Minister** reaffirmed Cambodia's close cooperation with and full support for the Philippines' ASEAN Chairmanship next year. With a view to deepening and strengthening bilateral relations, both ministers discussed the preparations for the 5th Joint Commission for Bilateral Cooperation between Cambodia and the Philippines, which will be hosted by Cambodia in 2026, with the exact date to be coordinated through diplomatic channels.

Phnom Penh, 26 October 2025

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការបរទេស**
**និងសហប្រតិបត្តិការអន្តរជាតិ**
**លេខ៖ បព ៤៦/២០២៥ កបទ.សអ**

សេចក្តីប្រកាសព័ត៌មាន

# លទ្ធផលនៃកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ានលើកទី៣០ កិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលអាស៊ានលើកទី៣៧ និងកិច្ចប្រជុំរួមរវាងរដ្ឋមន្ត្រីការបរទេស និងរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន

នៅថ្ងៃទី២៥ ខែតុលា ឆ្នាំ២០២៥ **ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមកិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ានលើកទី៣០ កិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលអាស៊ានលើកទី៣៧ និងកិច្ចប្រជុំរួមរវាងរដ្ឋមន្ត្រីការបទេស និងរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន នៅទីក្រុងគូឡាឡាំពួ ប្រទេសម៉ាឡេស៊ី។

## ១. កិច្ចប្រជុំរដ្ឋមន្ត្រីការបរទេសអាស៊ាន

កិច្ចប្រជុំបានបញ្ជាក់ជាថ្មីអំពីការប្តេជ្ញាចិត្តពង្រឹងការកសាងសហគមន៍អាស៊ានឆ្ពោះទៅកាន់ការសម្រេចបាននូវចក្ខុវិស័យសហគមន៍អាស៊ានឆ្នាំ២០៤៥ ដែលបានអនុម័តកាលពីដើមឆ្នាំនេះ ហើយបានពិភាក្សាអំពីវឌ្ឍននៃការអនុវត្តសន្ធិសញ្ញាមិត្តភាពនិងសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍ (TAC) និងបានរំលឹកអំពីសារៈសំខាន់នៃការពង្រឹងមជ្ឈភាពអាស៊ានក្នុងទំនាក់ទំនងជាមួយដៃគូខាងក្រៅ។

កិច្ចប្រជុំបានពិភាក្សាអំពីការតាមដានលើការវាយតម្លៃនិងសេចក្តីសម្រេចចិត្តរបស់ប្រមុខដឹកនាំអាស៊ានស្តីពីការអនុវត្តកិច្ចព្រមព្រៀងជាឯកច្ឆន្ទប្រាំចំណុច (5PC) និងបានបញ្ជាក់ថា 5PC នៅតែជាឯកសារគោលរបស់អាស៊ានក្នុងការដោះស្រាយវិបត្តិនៅមីយ៉ាន់ម៉ា។

កិច្ចប្រជុំបានស្វាគមន៍ការចូលរួមជាសមាជិកអាស៊ានពេញសិទ្ធិរបស់ទីម័រឡេស្តេ នៅពេលដែលទីម័រឡេស្តេបានតម្កល់លិខិតុបករណ៍ចូលជាភាគីនៃធម្មនុញ្ញអាស៊ាន និងលិខិតុបករណ៍ចូលជាភាគីនៃសន្ធិសញ្ញាស្តីពីតំបន់អាស៊ីអាគ្នេយ៍គ្មានអាវុធនុយក្លេអ៊ែរ (SEANWFZ) ហើយកិច្ចប្រជុំក៏បានអនុម័តអនុសាសន៍ស្តីពីការស្តារឡើងវិញវេទិកាតំបន់អាស៊ាន (ARF)។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា សមិទ្ធផល ដែលសម្រេចបានក្រោមភាពជាប្រធានអាស៊ានរបស់ម៉ាឡេស៊ី គឺជាការឆ្លុះបញ្ចាំងពីសេចក្តីប្រាថ្នារួមក្នុងការកសាងសហគមន៍អាស៊ានឱ្យកាន់តែស៊ីសង្វាក់គ្នា មានភាពធន់ និងផ្តោតលើប្រជាជនជាស្នូល ហើយបានសង្កត់ធ្ងន់ថា ការសម្រេច

អាសយដ្ឋាន: លេខ ៣ វិថី សម្តេច ហ៊ុន សែន
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា



ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល: mfaic@mfaic.gov.kh

បាននូវអាស៊ានដែលត្រៀមខ្លួនរួចជាស្រេចសម្រាប់អនាគតនិងប្រកបដោយចីរភាព គឺអាស្រ័យលើការប្ដេជ្ញាចិត្តយ៉ាងមុតមាំចំពោះកិច្ចសន្ទនា ការគោរពគ្នាទៅវិញទៅមក និងការដំណោះស្រាយជម្លោះប្រកបដោយសន្តិវិធី ស្របតាមច្បាប់អន្តរជាតិ ក៏ដូចជាធម្មនុញ្ញអង្គការសហប្រជាជាតិ និងអាស៊ាន។

ក្នុងឱកាសខួបអនុស្សាវរីយ៍លើកទី៥០ នៃ TAC នៅឆ្នាំ២០២៦ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់ថា សន្ធិសញ្ញានេះនៅតែជាក្របខ័ណ្ឌដ៏រឹងមាំ ដែលជួយលើកកម្ពស់បរិយាបន្នភាពជឿជាក់ និងភាពជាដៃគូ ហើយបានបញ្ជាក់ជាថ្មីអំពីការគាំទ្រតួគីយ៉េក្លាយជាដៃគូសន្ទនារបស់អាស៊ាន និងបានផ្ដោតសារៈសំខាន់ទៅលើការពង្រីកទំនាក់ទំនងជាមួយដៃគូដែលមានសក្ដានុពលថ្មីៗ ក្នុងបរិបទដែលភូមិសាស្ត្រពិភពលោកកំពុងវិវឌ្ឍ និងអាស៊ានកំពុងតែបន្តលូតលាស់ជាសហគមន៍ដ៏ស្វាហាប់។

## ២. <u>កិច្ចប្រជុំក្រុមប្រឹក្សាសហគមន៍នយោបាយ-សន្តិសុខអាស៊ានលើកទី៣០</u>

កិច្ចប្រជុំបានពិនិត្យលើវឌ្ឍនភាពនៃការអនុវត្ត និងបានឯកភាពលើរបាយការណ៍ពិនិត្យឡើងវិញបញ្ចប់អាណត្តិនៃផែនការលម្អិតនៃសហគមន៍នយោបាយ-សន្តិសុខអាស៊ានឆ្នាំ២០២៥ ហើយបានការប្ដេជ្ញាចិត្តក្នុងការអនុវត្តផែនការយុទ្ធសាស្ត្រសហគមន៍នយោបាយ-សន្តិសុខអាស៊ានឆ្នាំ២០៤៥ ឱ្យបានពេញលេញ និងពង្រឹងការអនុវត្តរបស់ខ្លួនដោយផ្អែកលើអនុសាសន៍នៃរបាយការណ៍បញ្ចប់អាណត្តិ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា ការបញ្ចប់ផែនការលម្អិតស្ដីពីសហគមន៍នយោបាយ-សន្តិសុខអាស៊ានឆ្នាំ២០២៥ ជាសញ្ញាសំខាន់ដែលបញ្ជាក់ពីការផ្លាស់ប្ដូរទៅរកចក្ខុវិស័យអាស៊ានឆ្នាំ២០៤៥ដែលផ្អែកលើភាពធន់ នវានុវត្តន៍ ភាពស្វាហាប់ និងអភិក្រមដែលផ្ដោតលើប្រជាជនជាស្នូល។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសង្កត់លើសារៈសំខាន់នៃការប្រើប្រាស់សិទ្ធិក្នុងការកោះប្រជុំរបស់អាស៊ាន ដើម្បីជំរុញកិច្ចសន្ទនា ការបង្ការតាមរយៈវិធីសាស្ត្រការទូត និងទំនាក់ទំនងប្រកបដោយស្ថាបនា តាមរយៈយន្តការដឹកនាំដោយអាស៊ាន។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានបញ្ជាក់ជាថ្មីអំពីការប្ដេជ្ញារបស់កម្ពុជា ចំពោះការពង្រឹងកិច្ចសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ក្នុងការប្រយុទ្ធប្រឆាំងទៅនឹងឧក្រិដ្ឋកម្មតាមប្រព័ន្ធបច្ចេកវិទ្យា និងការជំរុញរបៀបវារៈស្ដីពីស្ត្រី សន្តិភាព និងសន្តិសុខ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានស្វាគមន៍ភាពជោគជ័យក្នុងការរៀបចំកិច្ចប្រជុំកំពូលស្ត្រីអាស៊ានលើកទី២ និងបានកោតសរសើរភាពដឹកនាំរបស់ម៉ាឡេស៊ីក្នុងការលើកកម្ពស់តួនាទីដ៏សំខាន់របស់ស្ត្រីក្នុងយន្តការសន្តិភាព និងសន្តិសុខ ដែលបានបញ្ជាក់អំពីការប្ដេជ្ញាចិត្តរួមរបស់អាស៊ានក្នុងការលើកកម្ពស់តួនាទីរបស់ស្ត្រីជាអ្នករួមចំណែកដ៏សំខាន់ចំពោះសន្តិភាព និងភាពធន់។

## ៣. <u>កិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលអាស៊ានលើកទី៣៧</u>

កិច្ចប្រជុំក្រុមប្រឹក្សាសម្របសម្រួលអាស៊ានលើកទី៣៧ បានសម្ដែងការស្វាគមន៍យ៉ាងកក់ក្ដៅចំពោះការដាក់បញ្ចូលទីម័រឡេស្តេជាសមាជិកពេញសិទ្ធិអាស៊ាន និងបានកោតសរសើរចំពោះវឌ្ឍនភាពដ៏មានសារៈសំខាន់ដែលទីម័រឡេស្តេសម្រេចបាន ក្នុងការចូលរួមជាភាគីនៃលិខិតុបករណ៍គតិយុត្តនានារបស់អាស៊ាន ការលើកកម្ពស់ការត្រៀមខ្លួនខាងផ្នែកស្ថាប័ន ក៏ដូចជាការចូលរួមយ៉ាងសកម្មរបស់ទីម័រឡេស្តេនៅគ្រប់វិស័យនៃសសរស្តម្ភសហគមន៍ទាំងបីរបស់អាស៊ាន។ កិច្ចប្រជុំបានលើកទឹកចិត្ត

ឱ្យមានការបន្តផ្តល់ជំនួយបន្ថែមទៀតដល់ទីម័រឡេស្តេ ជាពិសេសតាមរយៈការចូលរួមវិភាគទាន ដើម្បីគាំទ្រដល់ដំណើរការរបស់អង្គភាពទីម័រឡេស្តេនៅលេខាធិការដ្ឋានអាស៊ាន និងបានគូសបញ្ជាក់អំពីសារៈសំខាន់ក្នុងការបំពេញតាមលក្ខខណ្ឌទាំងអស់ ដែលបានកំណត់នៅក្នុងផែនទីបង្ហាញផ្លូវសម្រាប់សមាជិកភាពពេញសិទ្ធិរបស់ទីម័រឡេស្តេក្នុងអាស៊ាន។ កិច្ចប្រជុំក៏បានពិភាក្សាអំពីការត្រៀមរៀបចំកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៧ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ ដែលនឹងប្រព្រឹត្តទៅឆាប់ៗខាងមុខ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានសង្កត់ធ្ងន់លើការប្តេជ្ញាចិត្តរបស់អាស៊ានក្នុងការកសាងសហគមន៍មួយប្រកបដោយបរិយាបន្ន សម្រាប់ប្រជាជនអាស៊ានទាំងមូល។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានអំពាវនាវឱ្យមានភាពជឿជាក់រវាងគ្នាកាន់តែខ្លាំងបន្ថែមទៀត ក្នុងចំណោមប្រទេសសមាជិកអាស៊ាន និងឱ្យមានការថែរក្សាការពារនូវឯកភាព និងមជ្ឈភាពអាស៊ាន ក្នុងការធ្វើទំនាក់ទំនងជាមួយបណ្តាប្រទេសដៃគូខាងក្រៅនានារបស់អាស៊ាន។ ដើម្បីឈានទៅសម្រេចបានគោលដៅទាំងនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជំរុញឱ្យអាស៊ានបន្តពង្រឹងសមត្ថភាពស្ថាប័ន ប្រើប្រាស់ធនធានដែលមានស្រាប់ប្រកបដោយប្រសិទ្ធភាព ក៏ដូចជាបង្កើតយន្តការនានា ដើម្បីតាមដាន និងធានាបាននូវការអនុវត្តប្រកបដោយប្រសិទ្ធភាព នៃគំនិតផ្តួចផ្តើមនានារបស់អាស៊ាន។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានអះអាងជាថ្មីនូវការគាំទ្ររបស់កម្ពុជាចំពោះសមាហរណកម្មសេដ្ឋកិច្ចតំបន់កាន់តែស៊ីជម្រៅ ការធ្វើឱ្យប្រសើរឡើងនូវភាពធន់នៃចង្វាក់ផ្គត់ផ្គង់ និងកំណើនដោយផ្អែកលើនវានុវត្តន៍។ **ឯកឧត្តម**ក៏បានបង្ហាញនូវការគាំទ្រយ៉ាងពេញលេញរបស់កម្ពុជា ចំពោះសំណើរបស់ប្រធានអាស៊ាន លើឯកសារលទ្ធផលនៃកិច្ចប្រជុំកំពូលអាស៊ានលើកទី៤៧ និងកិច្ចប្រជុំកំពូលពាក់ព័ន្ធ។

## ៤. កិច្ចប្រជុំរួមរវាងរដ្ឋមន្ត្រីការបរទេស និងរដ្ឋមន្ត្រីសេដ្ឋកិច្ចអាស៊ាន

កិច្ចប្រជុំបានកត់សម្គាល់លើសេចក្តីរាយការណ៍សង្ខេបរបស់ក្រុមការងារភូមិសាស្ត្រសេដ្ឋកិច្ចអាស៊ាន និងបានស្នើឱ្យមានភាពបន្ស៊ីគ្នាកាន់តែប្រសើរឡើងរវាងរវាងយុទ្ធសាស្ត្រនានា ដែលដាក់ចេញដោយសសរស្តម្ភផ្នែកនយោបាយ និងសេដ្ឋកិច្ច ដើម្បីជំនះលើភាពស្មុគស្មាញនិងភាពបាក់បែកនៃទិដ្ឋភាពភូមិសាស្ត្រនយោបាយ និងភូមិសាស្ត្រសេដ្ឋកិច្ច។ កិច្ចប្រជុំក៏បានលើកទឹកចិត្តឱ្យមានការផ្សារភ្ជាប់គ្នាជាមូលដ្ឋាននូវអនុសាសន៍នានារបស់ក្រុមការងារភូមិសាស្ត្រសេដ្ឋកិច្ចទៅក្នុងផែនការយុទ្ធសាស្ត្រសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៦-២០៣០ នាពេលខាងមុខ ដើម្បីធានានូវភាពស៊ីសង្វាក់គ្នាជាមួយនឹងទស្សនវិស័យធំទូលាយរបស់អាស៊ាន ដែលប្រកបដោយភាពធន់ បរិយាបន្ន និងសេដ្ឋកិច្ចប្រកបដោយចីរភាព។

នៅក្នុងឱកាសកិច្ចប្រជុំនេះ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានអំពាវនាវឱ្យមានការពង្រឹងឯកភាពអាស៊ាន និងការសម្របសម្រួលអន្តរសសរស្តម្ភ ដើម្បីដោះស្រាយនូវចំណុចប្រសព្វនៃក្តីបារម្ភរួមគ្នាខាងផ្នែកសេដ្ឋកិច្ច និងសន្តិសុខ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់លើភាពចាំបាច់ក្នុងការរៀបចំនូវអភិក្រមអន្តរសសរស្តម្ភដ៏ជាក់លាក់មួយ ដែលផ្សារភ្ជាប់ភាពស្រទាក់ក្រឡាគ្នារវាងវិស័យនយោបាយ សន្តិសុខ និងសេដ្ឋកិច្ច។ ដោយគូសបញ្ជាក់ជាថ្មីអំពីការគាំទ្ររបស់កម្ពុជាចំពោះពហុភាគីនិយម និងគោលការណ៍នានារបស់អង្គការពាណិជ្ជកម្មពិភពលោក **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកទឹកចិត្តអាស៊ានឱ្យដើរតួនាទីកាន់តែសកម្មបន្ថែមទៀត ក្នុងការរៀបចំច្បាប់សកលគ្រប់គ្រងពាណិជ្ជកម្មឌីជីថល ការសម្រួលការវិនិយោគ និងអន្តរកាលបៃតង។ **ឯកឧត្តម**

**ឧបនាយករដ្ឋមន្ត្រី** ក៏បានអំពាវនាវឱ្យមានការធ្វើឱ្យកាន់តែស៊ីជម្រៅនូវសមាហរណកម្មតំបន់តាមរយៈពាណិជ្ជកម្មក្នុងអាស៊ាន ការតភ្ជាប់ បរិវត្តកម្មឌីជីថល និងការអនុវត្តឱ្យបានទាន់ពេលវេលានូវក្របខណ្ឌគន្លឹះនានា ដូចជាផែនការយុទ្ធសាស្ត្រសហគមន៍សេដ្ឋកិច្ចអាស៊ានឆ្នាំ២០២៦-២០៣០ កិច្ចព្រមព្រៀងក្របខណ្ឌសេដ្ឋកិច្ចឌីជីថលអាស៊ាន និងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីក្នុងតំបន់។

## ៦. ពិធីចុះហត្ថលេខាលើលិខិតុបករណ៍ចូលជាភាគីនៃសន្ធិសញ្ញាមិត្តភាព និងកិច្ចសហប្រតិបត្តិការនៅអាស៊ីអាគ្នេយ៍

នៅក្នុងឱកាសកិច្ចប្រជុំខាងលើ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** និងរដ្ឋមន្ត្រីការបរទេសអាស៊ានផ្សេងទៀត បានអញ្ជើញចូលរួមជាសក្សីក្នុងពិធីចុះហត្ថលេខាលើលិខិតុបករណ៍ចូលជាភាគីនៃ TAC ដោយសាធារណរដ្ឋហ្វាំងឡង់។ **លោកជំទាវ** Elina Valtonen រដ្ឋមន្ត្រីការបរទេសនៃសាធារណរដ្ឋហ្វាំងឡង់ បានអះអាងពីការប្តេជ្ញាចិត្តរបស់ខ្លួនចំពោះគុណតម្លៃនិងគោលការណ៍របស់អាស៊ាន ចំពោះសន្តិសហវិជ្ជមាន ការគោរពគ្នាទៅវិញទៅមក និងសហប្រតិបត្តិការមិត្តភាពនៅអាស៊ីអាគ្នេយ៍។

## ៥. កិច្ចប្រជុំទ្វេភាគី

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានជួបពិភាក្សាទ្វេភាគីជាមួយលោកជំទាវ Ma. Theresa P. Lazaro រដ្ឋមន្ត្រីការបរទេសហ្វីលីពីន ដែលរដ្ឋមន្ត្រីទាំងពីរបានរំឭកអំពីទស្សនកិច្ចផ្លូវរដ្ឋប្រកបដោយជោគជ័យ និងផ្លែផ្កានៅកម្ពុជា របស់ **ឯកឧត្តម** Ferdinand Romualdez Marcos Jr. ប្រធានាធិបតីហ្វីលីពីន កាលពីខែកញ្ញា ឆ្នាំ២០២៥ ហើយក៏បានផ្លាស់ប្តូរយោបល់គ្នាលើការបង្កើតក្រុមអ្នកសង្កេតការណ៍អាស៊ាន ដើម្បីត្រួតពិនិត្យការអនុវត្តឱ្យបានពេញលេញ និងមានប្រសិទ្ធភាពនូវបទឈប់បាញ់រវាងកម្ពុជា និងថៃ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានបញ្ជាក់ជាថ្មីពីកិច្ចសហប្រតិបត្តិការជិតស្និទ្ធ និងការគាំទ្រពេញទំហឹងចំពោះតួនាទីជាប្រធានអាស៊ានរបស់ហ្វីលីពីន នៅឆ្នាំក្រោយ។ ក្នុងគោលបំណងពង្រឹង និងធ្វើឱ្យកាន់តែស៊ីជម្រៅនូវទំនាក់ទំនងទ្វេភាគី រដ្ឋមន្ត្រីទាំងពីរបានពិភាក្សាអំពីការត្រៀមរៀបចំកិច្ចប្រជុំគណៈកម្មការចម្រុះលើកទី៥ សម្រាប់កិច្ចសហប្រតិបត្តិការទ្វេភាគីរវាងកម្ពុជា និងហ្វីលីពីន ដែលគ្រោងរៀបចំ នៅកម្ពុជា ក្នុងឆ្នាំ២០២៦ ដោយកាលបរិច្ឆេទជាក់លាក់នឹងត្រូវសម្របសម្រួលតាមរយៈផ្លូវការទូត។

ថ្ងៃអាទិត្យ ៥កើត ខែកត្តិក ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី២៦ ខែតុលា ឆ្នាំ២០២៥